# ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

## សេចក្តីសង្ខេប

១. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ត្រូវបានរៀបចំឡើងដោយអង្គភាពគ្រប់គ្រងសមាសភាគទី ១ នៃគម្រោង នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គភាពគ្រប់គ្រងសមាសភាគទី ២ នៃគម្រោង នៃក្រសួងសាធារណការ និងដឹកជញ្ជូន។ អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារ (Task Team) របស់ធនាគារពិភពលោកដែលបានផ្តល់ការគាំទ្រ និងការណែនាំ។

២. ក្របខណ្ឌ ESMF នេះត្រូវបានរៀបចំឡើងជាផ្នែកមួយនៃគម្រោងការធ្វើឱ្យប្រសើរឡើងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (WaSSIP) ដែលនឹងត្រូវទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក (WBG) តាមរយៈឥណទានពីសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) និងរាជរដ្ឋាភិបាលកម្ពុជា។ ក្របខណ្ឌនេះ ត្រូវបានរៀបចំឡើង ដើម្បីធានាថាគម្រោងដែលទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក នឹងមិននាំមកនូវផលប៉ះពាល់អវិជ្ជមានចំពោះសង្គម និងបរិស្ថានក្នុងអំឡុង និងក្រោយពេលការអនុវត្តគម្រោងទាំងនេះឡើយ។ ទីតាំងក្រុមអនុគម្រោងជំហានដំបូងដែលបានកំណត់ក្រោមក្របខណ្ឌនៃគម្រោង WaSSIP នេះ រួមមានខេត្តមណ្ឌលគិរី ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តបាត់ដំបង។ ទីតាំងអនុគម្រោងផ្សេងទៀត នឹងត្រូវកំណត់ក្នុងអំឡុងពេលអនុវត្តន៍គម្រោង។

៣. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម នឹងផ្តល់ការណែនាំដល់អ្នកទទួលផល ដូចជា សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អង្គភាពស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ រដ្ឋាករទឹកខេត្ត ដើម្បីកាត់បន្ថយឱ្យនៅជាអប្បបរមា ឬសម្រាលផលប៉ះពាល់បរិស្ថាន និងក្តីបារម្ភផ្នែកសង្គម ដែលអាចកើតមានឡើង។ ESMF នេះនឹងត្រូវបានប្រើប្រាស់ជាក្របខណ្ឌ សម្រាប់ផ្តល់ការណែនាំដល់អនុគម្រោងទាំងអស់ ដែលស្ថិតក្រោមគម្រោងនេះ តាមរយៈដំណើរការវាយតម្លៃបរិស្ថាន ដូចជា ការវាយតម្លៃបរិស្ថានបឋម ការពិនិត្យបឋម ការកំណត់វិសាលភាព និង ចុងក្រោយ ត្រូវឆ្លងកាត់ការវាយតម្លៃផលប៉ះពាល់បរិស្ថានលម្អិត ប្រសិនបើចាំបាច់។

៤. គេរំពឹងថា គម្រោងនេះ ជារួមនឹងនាំមកនូវផលវិជ្ជមានកម្រិតដល់សង្គម តាមរយៈការផ្តល់ការផ្គត់ផ្គង់ទឹកស្អាតដល់ទីរួមខេត្ត និងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់តំបន់ជនបទ។ អត្ថប្រយោជន៍ទាំងនេះរួមមាន ការផ្តល់សេវាជាមូលដ្ឋានក្នុងទម្រង់ជាការផ្គត់ផ្គង់ទឹកស្អាត ដែលនាំឱ្យប្រជាជនដែលជាអ្នកទទួលផលសម្រេចបានលទ្ធផលសុខភាពល្អជាងមុន។ ការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ដល់ផ្ទះប្រជាពលរដ្ឋ ក៏នឹងជួយកាត់បន្ថយបន្ទុកការងារក្នុងការដងទឹក ដែលជាបន្ទុកការងារក៏ធ្ងន់ធ្ងរសម្រាប់សមាជិកគ្រួសារជាស្ត្រីផងដែរ។ ផលប៉ះពាល់ជាវិជ្ជមាន រួមមាន (i)-បង្កើនបរិមាណ និងគុណភាពទឹកស្អាតសម្រាប់បរិភោគ (ii)-កាត់បន្ថយជំងឺពាក់ព័ន្ធនឹងទឹក ដូចជាជំងឺរាករូស អាសន្នរោគ គ្រុនពោះវៀន និងកាត់បន្ថយការចំណាយលើសេវាថែទាំសុខភាពក្នុងគ្រួសារ (iii)-កាត់បន្ថយមរណភាព និងការ

ឈឺរបស់ទារក កុមារ និងមាតា ដោយសារសេវាសុខភាព និងអនាម័យមានភាពល្អជាងមុន (iv)-កាត់បន្ថយចម្ងាយទៅកាន់ប្រភពទឹកដែលនាំឱ្យស្ត្រី និងក្មេងស្រី មានពេលវេលាសម្រាប់ធ្វើការងារដែលមានប្រយោជន៍ជាងមុន។ ក្រៅពីផលវិជ្ជមានសំខាន់ៗទាំងនេះ គម្រោងនេះក៏អាចបង្កផលប៉ះពាល់អវិជ្ជមានតិចតួចផងដែរ។ ការវាយតម្លៃលើផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើង ត្រូវបានធ្វើឡើងតាមរយៈការចុះទៅដល់ទីតាំងជាក់ស្តែង ការពិភាក្សាជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងអ្នកទទួលផល ការប្រើប្រាស់ប្រភពព័ត៌មានដែលមានស្រាប់ជាដើម។ បញ្ហា និងក្តីបារម្ភផ្នែកបរិស្ថាន ដែលអាចកើតមានឡើង មានដូចជា៖ (i)-ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងអំឡុងពេលសាងសង់ (ii)-ការចោលសំណល់ភក់ ក្នុងអំឡុងដំណើរការស្ថានីយផ្គត់ផ្គង់ទឹកស្អាត និងស្ថានីយប្រព្រឹត្តកម្មទឹកកករខ្វក់ និង (iii)-គុណភាពទឹក។

៥. របាយការណ៍ពិនិត្យបឋមលើអនុគម្រោង នឹងកំណត់ពីគោលនយោបាយការពារផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ធនាគារពិភពលោកដែលត្រូវអនុវត្តន៍សម្រាប់គម្រោងនេះ ក៏ដូចជាកំណត់ពីពេលវេលា និងរបៀបដែលត្រូវអនុវត្តន៍ ឬមិនអនុវត្តន៍គោលនយោបាយការពារផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក។ គម្រោងនេះ នាំឱ្យមានការអនុវត្តគោលនយោបាយការពារផលប៉ះពាល់បរិស្ថានចំនួនប្រាំ ដូចជា គោលនយោបាយស្តីពីការការវាយតម្លៃបរិស្ថាន (OP/BP 4.01) ធនធានវប្បធម៌រូបវ័ន្ត (OP/BP 4.11) ជម្រកធម្មជាតិ (OP/BP 4.04) សុវត្ថិភាពទំនប់ទឹក (OP/BP 4.37) និងគោលនយោបាយច្បាប់មួយស្តីពីគម្រោងដែលស្ថិតនៅលើផ្លូវទឹកអន្តរជាតិ (OP/BP 7.50) ដែលក្នុងនោះគោលនយោបាយការពារផលប៉ះពាល់ទាំងនេះ ត្រូវយកមកអនុវត្តន៍ដោយសារតែគេរំពឹងថានឹងមានផលប៉ះពាល់ក្នុងទ្រង់ទ្រាយតូច ដែលពុំអាចប្រែត្រឡប់ទៅរកជាតុដើមវិញ ចេញពី (i)-ការងារសាងសង់ ដូចជា ការតបណ្តាញផ្គត់ផ្គង់ទឹក ការសាងសង់បណ្តាញលូ (ii)-ប្រភពទឹកដែលអាចយកចេញពីស្ទឹងធម្មជាតិ (iii)-មានទីតាំងស្ថិតនៅក្នុងតំបន់បេតិកភណ្ឌវប្បធម៌ (iv)-ជាបម្រុងប្រយ័ត្នជាមុន ក្នុងករណីដែលអាចមានការតភ្ជាប់ប្រភពទឹកជាមួយនឹងទំនប់ដែលជិតខាង និង (v)-ការវិនិយោគផ្សារភ្ជាប់ជាមួយនឹងផ្លូវទឹកអន្តរជាតិ។

៦. បច្ចុប្បន្ននេះ ហានិភ័យសង្គមរបស់គម្រោងនេះ ត្រូវបានដាក់ចាត់ចំណាត់ថ្នាក់ថាមានកម្រិតមធ្យម។ គេរំពឹងថា អាចមានផលប៉ះពាល់សង្គមក្នុងកម្រិត និងវិសាលភាពខុសៗគ្នា ចេញពីការអនុវត្តអនុគម្រោង អាស្រ័យទៅតាមវិសាលភាព និងទីតាំងនៃអនុគម្រោងទាំងនោះ ដែលគេមិនទាន់បានកំណត់លម្អិតនៅឡើយ។ ផ្អែកតាមកិច្ចពិគ្រោះយោបល់បឋមជាមួយអ្នកទទួលផលពាក់ព័ន្ធនឹងការវិនិយោគដែលអាចនឹងមាន គម្រោងនេះទំនងជានាំឱ្យមានការអនុវត្តគោលនយោបាយការពារផលប៉ះពាល់សង្គមចំនួនពីររបស់ធនាគារពិភពលោក៖ គោលនយោបាយស្តីពីជនជាតិដើមភាគតិច (OP/BP 4.10) និងគោលនយោបាយស្តីពីការផ្លាស់ប្តូរទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12)។

៧. នីតិវិធីសម្រាប់ពិនិត្យបឋម ពិនិត្យឡើងវិញ ផ្តល់ការអនុញ្ញាត និងអនុវត្តឧបករណ៍ការពារផលប៉ះពាល់អនុគម្រោង មានគោលបំណងធានាឱ្យមានការឆ្លើយតបឱ្យបានគ្រប់ជ្រុងជ្រោយចំពោះការព្រួយបារម្ភលើផ្នែកបរិស្ថាន និងសង្គម តាមរយៈការរៀបចំស្ថាប័ន និងនីតិវិធីនានា ដែលគម្រោងប្រើប្រាស់សម្រាប់គ្រប់គ្រងការកំណត់ ការរៀបចំ ការឯកភាព និងការអនុវត្តអនុគម្រោង។ នីតិវិធី ESMF ត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងជាក់ច្បាស់ជាមួយនឹងវដ្តអនុគម្រោងនឹងត្រូវបានកំណត់នៅក្នុងគម្រោងនេះ ដែលគេអាចយកទៅបញ្ចូលក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង (POM)។

៨. នីតិវិធីរាប់ចាប់ពីការពិនិត្យបឋម រហូតដល់ការពិនិត្យតាមដាន និងរៀបចំរបាយការណ៍ មានជាជំហានដូចខាងក្រោម៖

ជំហានទី មួយ – ការពិនិត្យលើការបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់អនុគម្រោង ដែលអាចដាក់បញ្ចូលក្នុងគម្រោង នឹងមានការពិនិត្យបឋមលើអនុគម្រោងសក្តានុពល ដើម្បីកំណត់ថាតើអនុគម្រោងទាំងនេះបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យកំណត់ពីភាពសមស្រប ដោយប្រើប្រាស់ទម្រង់ពិនិត្យបឋម (Screening Form) ក្នុងឧបសម្ព័ន្ធទី ១។ អនុគម្រោងដែលអាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់លើដែនជម្រកធម្មជាតិ ឬដែលតម្រូវឱ្យមានការធ្វើលទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត និងពុំអាចទទួលបានហិរញ្ញប្បទានពីគម្រោងនេះឡើយ។

ជំហានទី ពីរ – ការពិនិត្យបឋមបច្ចេកទេស និងការកំណត់ប្រភេទអនុគម្រោង នៃរាល់អនុគម្រោទាំងអស់ត្រូវឆ្លងកាត់ដំណើរការពិនិត្យបឋម ដោយប្រើប្រាស់ទម្រង់ពិនិត្យបឋមលើការការពារផលប៉ះពាល់ក្នុងឧបសម្ព័ន្ធទី ១ ដើម្បីកំណត់ពីប្រភេទសមស្របនៃអនុគម្រោងស្របតាមកម្រិតនៃផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើង និងស្របតាមគោលការណ៍ណែនាំរបស់ធនាគារ (ដូចជា ប្រភេទ A B C ឬ FI)។ ទម្រង់ពិនិត្យបឋមនឹងធ្វើការកំណត់ពីឧបករណ៍ការពារផលប៉ះពាល់សមស្របដែលត្រូវយកមកអនុវត្តន៍ ទៅតាមប្រភេទនៃសកម្មភាព និងកម្រិតផលប៉ះពាល់ ឬការរំខានដែលអាចកើតមានឡើង។

ជំហានទី បី – កំណត់ពីឧបករណ៍ការពារផលប៉ះពាល់

ក្នុងជំហានទីបីនេះ អង្គភាពគ្រប់គ្រងគម្រោងនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវជួយរៀបចំឧបករណ៍ការពារផលប៉ះពាល់ដែលចាំបាច់ត្រូវមាន។

ជំហានទី បួន – ការវាយតម្លៃ និងកិច្ចពិគ្រោះយោបល់

ឧបករណ៍ការពារផលប៉ះពាល់ នឹងត្រូវប្រើប្រាស់ដោយទីប្រឹក្សាដែលមានសមត្ថភាព ឬអ្នកជំនាញបច្ចេកទេស ដើម្បីកំណត់អំពីកម្រិតនៃផលប៉ះពាល់អវិជ្ជមាន ដែលបង្កឡើងដោយអនុគម្រោង និងសកម្មភាពដែលត្រូវបានស្នើឡើង មុនពេលចាប់ផ្តើមធ្វើការងារអ្វីមួយ។

ជំហានទី ប្រាំ – ការរៀបចំផែនការគ្រប់គ្រង

បន្ទាប់ពីឧបករណ៍ការពារផលប៉ះពាល់សមស្របត្រូវបានកំណត់រួច នឹងមានការវាយតម្លៃសមស្របលើផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចបង្កឡើងដោយសារគម្រោងក្នុងអំឡុងពេលអនុវត្តន៍អនុគម្រោងត្រូវ

បានបញ្ចប់រួចរាល់ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ឬ ECOP នឹងត្រូវរៀបចំឡើង និងដាក់បញ្ចូលទៅក្នុងឯកសារដេញថ្លៃការងារសាងសង់។ ESMP ត្រូវបញ្ចូលយ៉ាងហោចណាស់ ECOP ដែលមានលក្ខណៈស្តង់ដារ និងវិធានការសម្រាលផលប៉ះពាល់តាមការដ្ឋាននីមួយៗ រួមនឹងកម្មវិធីពិនិត្យតាមដានបរិស្ថាន។ អាស្រ័យទៅតាមស្ថានភាពរបស់អនុគម្រោង (ឧទាហរណ៍ ដូចជាសកម្មភាពរបស់រដ្ឋករទឹក ដែលមានផលប៉ះពាល់តិចតួច) គេអាចប្រើប្រាស់វិធានការសម្រាលដែលមានលក្ខណៈទូទៅ ដូចជា ECOP ជាដើម។

ជំហានទី ប្រាំមួយ – ការអនុវត្តវិធានការសម្រាប់សម្រាលផលប៉ះពាល់

វិធានការសម្រាលផលប៉ះពាល់ និងគ្រប់គ្រង ដូចរៀបរាប់នៅក្នុង ESMP/ECOP (ឧទាហរណ៍ លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសទីតាំង ការគ្រប់គ្រងការដ្ឋានសំណង់ឱ្យបានត្រឹមត្រូវ វិធានការត្រួតពិនិត្យ) និងត្រូវអនុវត្តន៍ដោយក្រុមហ៊ុនម៉ៅការសាងសង់ ក្រោមការត្រួតពិនិត្យរបស់អង្គភាពគ្រប់គ្រងគម្រោងនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន។

ជំហានទី ប្រាំពីរ – ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍

ចាំបាច់ត្រូវមានការពិនិត្យតាមដាន ដើម្បីប្រមូលព័ត៌មានកំណត់ពីប្រសិទ្ធភាពនៃការអនុវត្តវិធានការសម្រាសផលប៉ះពាល់ និងគ្រប់គ្រង និងដើម្បីធានាថា ក្រុមហ៊ុនម៉ៅការពិតជាបានអនុវត្តន៍ទៅតាម ESMP ដែលបានឯកភាព។ អង្គភាពគ្រប់គ្រងគម្រោង (ដែលមានការគាំទ្រពីទីប្រឹក្សាបច្ចេកទេសពាក់ព័ន្ធ) មានភារកិច្ចពិនិត្យតាមដានភាពអនុលោមរបស់ក្រុមហ៊ុនម៉ៅការក្នុងអំឡុងពេលនៃការអនុវត្តទាំងមូល។

៩. ដើម្បីគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថាន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន បានរៀបចំក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ និងក្របខណ្ឌគោលនោបាយជនជាតិដើមភាគតិច ផ្អែកតាមការវាយតម្លៃសង្គមបឋម ក៏ដូចជាក្រមខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម។ លើសពីនេះ មន្ត្រីបង្គោលទទួលបន្ទុកការការពារផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានតែងតាំងដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូនរួចហើយសម្រាប់ការរៀបចំ និងការអនុវត្តគម្រោងនេះ។ ការអនុវត្តនៃការការពារផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវគោរពតាមការរៀបចំ ការអនុវត្តគម្រោងទៅតាមការចាត់ចែងរបស់ក្រសួងនីមួយៗ។

១០. សៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង មានផ្នែកស្តីពីបញ្ហា/នីតិវិធីបរិស្ថាន ការដោះស្រាយផលប៉ះពាល់ ការផ្តល់សំណង និងផែនការជនជាតិភាគតិច។ ផ្នែកទាំងនេះ ត្រូវបង្ហាញពីតំណភ្ជាប់ទៅកាន់៖ (i)-ការពិនិត្យបឋមលើគម្រោង (ii)-សកម្មភាពសម្រាលផលប៉ះពាល់ដែលសមស្រប និង/ឬ ក្រមប្រតិបត្តិបរិស្ថាន (ECOP) (iii)-ទម្រង់ការពារផលប៉ះពាល់ដែលត្រូវធ្វើតេស្តសាកល្បងជាមួយនៅកម្រិតអនុគម្រោង (iv)-ការរៀបចំឧបករណ៍/ការណែនាំបន្ថែម និង (v)-ព័ត៌មានលម្អិតអំពីរបៀបធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើការការពារផលប៉ះពាល់។

១១.   លើសពីនេះ គម្រោងនេះ បានបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់មូលដ្ឋាន (ខេត្ត ស្រុក និងឃុំ) ដែលត្រូវដឹកនាំដោយអភិបាលខេត្ត ឬអភិបាលរងខេត្ត អភិបាលស្រុក និងមេឃុំ។ តំណាងមកពីគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោងនឹងត្រូវជ្រើសរើសចេញពីក្នុងចំណោមប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងឱ្យធ្វើជាសមាជិកនៃយន្តការដោះស្រាយផលប៉ះពាល់។  ក្នុងករណីសហគមន៍ជនជាតិដើមភាគតិច នឹងមានការបង្កើតគណៈកម្មាធិការនៅថ្នាក់ឃុំ និងត្រូវមានការរៀបចំដំណើរការពិគ្រោះយោបល់ដោយសេរីជាមុនផ្អែកតាមព័ត៌មានត្រឹមត្រូវ ក៏ដូចជាមានការបង្កើតនូវរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចចិត្តដែលមានលក្ខណៈពិសេសសម្រាប់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាត្រូវមានតុល្យភាពយេនឌ័រ និងតុល្យភាពអន្តរជំនាន់។